# *សិក្ខាសាលាស្តីពីការអនុវត្តន៍ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម*

## (OPCAT)

សន្ទរកថាថ្លែងបើក ដោយលោក គ្រីស្តូហ្វ ប៉េស្ស៊ូ
តំណាងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីរាប់អាន

នៅឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានអះអាងជាថ្មីអំពីការប្តេជ្ញាចិត្តដើម្បីបង្ការការធ្វើទារុណកម្ម តាមរយៈការផ្តល់សច្ចាប័នលើពិធិសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្មដែលគេស្គាល់ថា OPCAT ។ ប្រទេសកម្ពុជាអាចមានមោទនភាពដោយសារថាជាប្រទេសមួយក្នុងចំណោមប្រទេសដំបូងគេនៅក្នុងតំបន់នេះ ដែលផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះ ហើយក៏ជាប្រទេសតែមួយគត់នៃសមាគមអាស៊ានដែលបានធ្វើដូច្នេះ។

ជំហាននេះរិតតែសំខាន់ថែមទៀត ដោយសារថា ការឈឺចាប់បំផុតដែលបង្កឡើងដោយអំពើទារុណកម្មលើរាង្គកាយ និងព្រលឹងរបស់ជនរងគ្រោះនៃប្រទេសនេះនៅក្នុងរបបគ្រប់គ្រងរបស់ខ្មែរក្រហម។ ក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) បានកំណត់កាលបរិច្ឆេទបើកសវនាការបឋម ដើម្បីកាត់ទោស កាំង ហ្កិច អ៊ាវ ហៅឌុច ដែលជាអតីតប្រធានគុកទួលស្លែង ឬគុកស២១ មណ្ឌលសន្តិសុខ CPK ដែលមានមនុស្សរហូតដល់២០០០០ នាក់ត្រូវបានធ្វើទារុណកម្ម និងសំលាប់នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។

ទារុណកម្មមិនមែនមានតែក្នុងអតីតកាល  ឬមិនមែនមានតែនៅកម្ពុជានោះទេ។ វាគឺជាការអនុវត្តន៍របស់មនុស្សទូទៅ និងការប្រយុទ្ធប្រឆាំងនឹងអំពើនេះ ដែលនៅមិនទាន់សំរេចទាំងស្រុងនៅឡើយ។ ការប្រយុទ្ធប្រឆាំងនេះនឹងបន្ត ហើយគួរតែបន្តធ្វើតទៅទៀត។ វាគឺជាការតស៊ូមួយរវាងភាពភ្លឺនិងភាពងងឹតនៅក្នុងខ្លួនមនុស្ស។ ការត្រឡប់ថយក្រោយអាចដើរតាមដានចាស់ និងធ្វើឲ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងនានា ដោយយើងបានឃើញតាំងពីដើមឆ្នាំ២០០០ ការលេចឡើង

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org  Website: http://cambodia.ohchr.org

ជាថ្មីនូវការធ្វើទារុណកម្មក្នុងបរិបទនៃអ្វីដែលគេហៅថា " សង្គ្រាមភេរវកម្ម " ។ យើងនឹកឃើញអំពីទិដ្ឋភាពក្នុងពន្ធនាគារ អាប៊ូ ហ្គ្រេប នៅប្រទេសអ៊ីរ៉ាក់ ឬពន្ធនាគារគ្វាន់តាណាមូ ។ រូបខ្ញុំផ្ទាល់ធ្លាប់បានទៅប្រទេសអ៊ីរ៉ាក់នៅឆ្នាំ២០០៣ ហើយខ្ញុំស្ថិតនៅក្នុងក្រុមទីមួយដែលបានទៅសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារអាប៊ូ ហ្គ្រេប ដែលឃុំគ្រងដោយទាហានអាមេរិកកាំង ។

នៅកម្ពុជា ទារុណកម្មលែងមានក្នុងគោលនយោបាយរដ្ឋតាំងពីឆ្នាំ១៩៧៩ មក។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនោះ ការប្រើអំពើទារុណកម្មបានថយចុះ ដោយសារមានកិច្ចខិតខំប្រឹងប្រែងបានធ្វើឡើងដើម្បីទប់ស្កាត់បញ្ហានេះ។ ប៉ុន្តែបញ្ហានេះមិនទាន់ជំនះបានទាំងស្រុងនៅឡើយទេ យើងឮអំពីករណីមួយចំនួន ដែលអ្នកជាប់ឃុំនៅស្ថានីយនគរបាលត្រូវគេវាយដំបង្ខំឲ្យឆ្លើយសារភាពអំពីបទល្មើសដែលបានចោទប្រកាន់ ។ នៅតាមពន្ធនាគារ លើកលែងពន្ធនាគារខ្លះ ការធ្វើទារុណម្មបានបញ្ឈប់។ **ប៉ុន្តែសួរថាតើបច្ចុប្បន្ននេះ ការធ្វើទារុណកម្មមានកំរិតណានៅកម្ពុជា?** និយាយតាមត្រង់ទៅ ខ្ញុំយល់ថាគ្មាននរណាម្នាក់ដឹងប្រាកដឡើយ។ នេះក៏ព្រោះតែអ្នកដែលប្រើទារុណកម្ម មិនរាយការណ៍អំពីបញ្ហានេះ។ អ្នកដែលដឹងអំពីបញ្ហានេះក្នុងស្ថានីយនគរបាល ឬពន្ធនាគារ មិនហ៊ានរាយការណ៍អំពីរឿងនេះ។ ជារឿយៗជនរងគ្រោះ មិនប្តឹងផ្តល់ដោយខ្លាចមានការដាក់ទោសទណ្ឌថែមទៀត ហើយពេលមានអ្នកប្តឹងទៅតុលាការជារឿយៗ ចៅក្រមមិនសូវអើពើចំពោះរឿងនេះទេ។ ដូច្នេះហើយទើបទារុណកម្មគឺជាបញ្ហាមួយ ដែលលំបាកចងក្រងជាឯកសារនិងធ្វើការប្រយុទ្ធប្រឆាំង។

ខ្ញុំសូមងាកមកពិធិសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) វិញ។ វាគឺជាសន្ធិសញ្ញាសិទ្ធិមនុស្សថ្មីមួយ។ វាបង្កើតនូវក្របខ័ណ្ឌថ្មីមួយសំរាប់ធានាថាទារុណកម្មនិងការប្រព្រឹត្តឯទៀតដែលឃោរឃៅ អមនុស្សធម៌ មិនអាចកើតមាននៅក្នុងប្រទេស តាមរយៈការបង្កើតយន្តការពីរស្របគ្នា ។

នៅកំរិតអន្តរជាតិ គេបានបង្កើតគណៈកម្មាធិការមួយ ដែលគេហៅថា អនុគណៈកម្មាធិការបង្ការទារុណកម្ម(SPT) ។ គណៈកម្មាធិការនេះមានអាណត្តិធ្វើដំណើរទៅកាន់ប្រទេសទាំងឡាយដែលបានផ្តល់សច្ចាប័នលើពិធិសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) ដើម្បីទស្សនាកន្លែងឃុំឃាំងនានា ធ្វើការវាយតំលៃអំពីស្ថានការណ៍នៃការធ្វើទារុណកម្ម និងផ្តល់យោបល់ទៅរដ្ឋាភិបាលអំពីវិធានការដែលអាចចាត់ឡើងដើម្បីទប់ស្កាត់បញ្ហានេះ។ គណៈកម្មាធិការនេះមានសមាសភាពអ្នកជំនាញការឯករាជ្យដែលត្រូវបានជ្រើសតាំងដោយរដ្ឋភាគីនានា ហើយថ្ងៃនេះយើងទាំងអស់គ្នាមានកិត្តិយសដោយមានការចូលរួមពីសមាជិកមួយរូបនៃអនុគណៈកម្មាធិការបង្ការទារុណកម្ម(SPT) បណ្ឌិត ហាន់ ដ្រាមិនស្គី ភីធីសិន ដើម្បីណែនាំប្រាប់យើងទាំងអស់គ្នាឲ្យបានស្គាល់អំពីការងាររបស់អនុគណៈកម្មាធិការនេះ។

ប៉ុន្តែគណៈកម្មាធិការអន្តជាតិមួយនេះ អាចធ្វើទស្សនកិច្ចនៅប្រទេសមួយតែម្តងម្កាលប៉ុណ្ណោះ ។ ដូច្នេះហើយ ដើម្បីធានាការឃ្លាំមើលឲ្យបានទៀងទាត់អំពីប្រព្រឹត្តកម្មទៅលើអ្នកជាប់ឃុំឃាំង ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) ស្នើឲ្យមានការបង្កើតស្ថាប័នជាតិមួយនៅក្នុងប្រទេសនីមួយៗ ដែលគេឲ្យឈ្មោះថា **យន្តការបង្ការថ្នាក់ជាតិ**(NPM) ។ យន្តការនេះមានមុខងារធ្វើទស្សកិច្ចជាទៀងទាត់នៅកន្លែងឃុំឃាំង (ពន្ធនាគារ ស្ថានីយនគរបាល និង

កន្លែងឯទៀតដែលអាជ្ញាធរឃុំមនុស្សផ្ទុយនឹងឆន្ទះរបស់ខ្លួន) ដើម្បីធានាថាទារុណកម្ម និងការប្រព្រឹត្តឯទៀតដែលឃោរឃៅ អមនុស្សធម៌ នឹងមិនអាចកើតមានឡើយ។ស្រដៀងគ្នានឹងអនុគណៈកម្មាធិការបង្ការទារុណកម្ម(SPT) ដែរ ស្ថាប័នជាតិមួយនេះត្រូវតែមានសមាសភាពសមាជិកឯករាជ្យដែលត្រូវអនុវត្តមុខងារភារកិច្ចរបស់ខ្លួន**ទាំងស្រុង** និង**ដោយមិនលំអៀង**។

សិក្ខាសាលានេះមានគោលបំណងរិះរកអំពីវិធីសាស្ត្រដែលល្អបំផុតអាចឲ្យកម្ពុជាបង្កើតយន្តការបង្ការថ្នាក់ជាតិ (NPM) ។

ខ្ញុំដឹងថាមានអ្នកខ្លះសង្ស័យអំពីលទ្ធភាពសំរាប់កម្ពុជាក្នុងការបង្កើតស្ថាប័នមួយដែលឯករាជ្យពិតប្រាកដ ។ ពួកគេនិយាយថាជាប្រវត្តិសាស្ត្រមិនមានស្ថាប័នណាមួយឯករាជ្យទេនៅក្នុងប្រទេសនេះ។

គោលការណ៍សំខាន់បំផុតដែលដឹកនាំការងាររបស់យន្តការបង្ការថ្នាក់ជាតិ(NPM) គឺ**ឯករាជ្យភាពនៃប្រតិបត្តិការការងាររបស់ខ្លួន។** ក្រៅពីការបង្កើតឡើងដោយច្បាប់ និងការប្រើប្រាស់ថវិការដ្ឋ យន្តការបង្ការថ្នាក់ជាតិ(NPM) ត្រូវប្រតិបត្តិការការងាររបស់ខ្លួនដោយឯករាជ្យ។ នេះគឺជាសេចក្តីតម្រូវរបស់គោលការណ៍ទីក្រុងប៉ារីស ។ តើគោលការណ៍នេះមានន័យដូចម្តេច?

មានន័យថាសមាជិករបស់យន្តការនេះ ពេលធ្វើទស្សនកិច្ចនៅពន្ធនាគារនិងសើបអង្កេតការចោទប្រកាន់ណាមួយអំពីការធ្វើទារុណកម្ម គួរតែអនុវត្តការងារនោះដោយ**សុចរិតទៀងត្រង់ដើម្បីរកឲ្យឃើញនិងកំណត់អំពីការពិត** ហើយមិនត្រូវការពារជនល្មើសដែលជាមន្ត្រីពាក់ព័ន្ធក្នុងករណីនោះឡើយ។ ប្រសិនជាការធ្វើទារុណកម្មកើតមានមែន ពួកគេគួរចងក្រងជាឯកសារហើយរាយការណ៍។ ប្រសិនការធ្វើទារុណកម្មមិនបានកើតមានទេ ពួកគេគួររាយការណ៍ទៅតាមនោះ។

បើមុខងាររបស់យន្តការបង្ការថ្នាក់ជាតិ(NPM) គឺត្រូវ**បំបាត់ទារុណកម្ម** ពួកគេត្រូវតែប្រឈមមុខទៅនឹងការពិត ដែលនេះគឺជាមធ្យោបាយតែមួយគត់ក្នុងការដោះស្រាយបញ្ហា។ នេះជា**លក្ខខណ្ឌសំរាប់ភាពអាចជឿទុកចិត្តបាន** ក្នុងក្រសែភ្នែករបស់មនុស្សរាល់គ្នា ៖ ជនរងគ្រោះ ជនល្មើស រដ្ឋាភិបាល និងសាធារណៈជន។

**ភាពអាចជឿទុកចិត្តបានគឺមិនអាចខ្វះបានឡើយ សំរាប់ការអនុវត្តមុខងាររបស់ខ្លួន។** ប្រសិនជាគេឃើញថាគ្មានសុចរិតទៀងត្រង់ និងមានភាពលំអៀងក្នុងការងាររបស់ខ្លួននោះ ជនរងគ្រោះនឹងមិនសហការជាមួយយន្តការនេះឡើយ ហើយជនល្មើសនឹងធ្វើជាមិនដឹងមិនឮ។ ហើយបើមានការធ្វើទារុណកម្ម អំពើនោះនឹងនៅតែបន្តធ្វើ។ អ្វីដែលនឹងកើតមាននោះគឺស្ថាប័នមួយការិយាធិបតេយ្យដែលបិទបាំងទារុណកម្ម និងការពារជនល្មើស។

ខ្ញុំមិនគិតថានេះជាអ្វីដែលរដ្ឋាភិបាលចង់បាននោះទេ។ ខ្ញុំមិនគិតថានេះជាអ្វីដែលអ្នកជាប់ឃុំឃាំងរំពឹងថានឹងមានដែរ។ ខ្ញុំមិនគិតថានេះជាអ្វីដែលប្រទេសកម្ពុជាចង់បាននោះឡើយ។

ការបង្កើតយន្តការបង្ការថ្នាក់ជាតិ(NPM) មួយឯករាជ្យពិតប្រាកដ គឺជាឱកាសមួយក្នុងការបើកទំព័រប្រវត្តិសាស្ត្រលក្ខណៈជាស្ថាប័ន ហើយមិនត្រឹមតែបង្ហាញដល់មន្ត្រីប្រតិបត្តិច្បាប់និង

អាជ្ញាធរមានសមត្ថកិច្ចឃុំឃាំង ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់តំបន់ និងពិភពលោកទាំងមូលថា ទារុណកម្មដែលកើតមានក្នុងអតីតកាលនឹងមិនត្រូវបានអត់ឱនទោសឡើយនៅក្នុងប្រទេសនេះ។ ខ្ញុំដឹងថា នេះបានក្លាយជាគោលនយោបាយរបស់ព្រះរាជាណាចក្រកម្ពុជាហើយ៖ យន្តការបង្ការថ្នាក់ជាតិ(NPM) នឹងជួយប្រែក្លាយគោលនយោបាយនេះទៅជាការអនុវត្តន៍ជាក់ស្តែង។ ការនេះនឹងធ្វើឲ្យប្រទេសកម្ពុជា ក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសជើងឯកដទៃទៀត ក្នុងការតស៊ូជាអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងទារុណកម្ម។

ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការិយាល័យយើងខ្ញុំ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សបាននឹងកំពុងជួយដល់រាជរដ្ឋាភិបាល ហើយលោកអាចបន្តពឹងពាក់លើការបន្តជួយគាំទ្ររបស់យើងខ្ញុំក្នុងន័យស្ថាបនា។

យើងខ្ញុំសូមជូនពរឲ្យសិក្ខាសាលានេះដំណើរការប្រកបដោយជោគជ័យ

សូមអរគុណ